# ព្រះរាជក្រម

នស/រកម/១២១៩/០២៥

# យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល លេខ ... ថ្ងៃទី ... ឆ្នាំ ... ម៉ោង ...
បញ្ជូនទៅ ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

# ឆ្នាំ ២០២០

# ជំពូកទី១

## ថវិកាថ្នាក់ជាតិ

**មាត្រា១ ._**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ វិភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន៣០ ៣៩៥ ៨៥៥លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត...........................................២៣ ៨៩៩ ៣២៤លានរៀល
- ចំណូលមូលធន...........................................៦ ៤៩៦ ៥៣១លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស................................ ១៩៣ ៣៤១លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស............................. ៦ ៣០៣ ១៩០លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ...........................................................២៥០ ០០០លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ...................................................៦ ០៥៣ ១៩០លានរៀល។

**មាត្រា២ ._**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង៣១ ០៩៥ ៨៥៥លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត...........................................១៨ ០៣៦ ៨៨៤លានរៀល
- ចំណាយមូលធន...........................................១៣ ០៥៨ ៩៧១លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

............................................................... ៥ ៨៩៩ ៨៥៩លានរៀល

- ដោយថវិកាថ្នាក់ជាតិ................................៥ ៦៤៩ ៨៥៩លានរៀល
  - គម្រោងវិនិយោគផ្ទាល់............... ៥ ០១៩ ៨៥៩លានរៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ............................................ ៦៣០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ

..........................................................២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

..................................................................៦ ០៥៣ ១៩០លានរៀល

គ- ការទូទាត់ការខ្ចី........................................ ១ ១០៥ ៩២២លានរៀល។

**មាត្រា៣ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង១៨ ០៣៦ ៨៨៥លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ .-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ត្រូវបានកំណត់ស្មើនឹង៣៧ ៤២៣ ៦២៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា.............................. ១៣ ០៥៨ ៩៧១លានរៀល
- ឥណទានទូទាត់................................ ១៣ ០៥៨ ៩៧១លានរៀល។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា................................ ៥ ៨៩៩ ៨៥៩លានរៀល
- ឥណទានទូទាត់....................................... ៥ ៨៩៩ ៨៥៩លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា..............................៦ ០៥៣ ១៩០លានរៀល
- ឥណទានទូទាត់...................................៦ ០៥៣ ១៩០លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា..............................១ ១០៥ ៩២២លានរៀល
- ឥណទានទូទាត់.................................. ១ ១០៥ ៩២២លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង"**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦ ._**

គុណភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលត្រូវបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិមានបង្ហាញនៅក្នុងតារាង "**ង**" ភ្ជាប់មកជាមួយច្បាប់នេះ ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- ចំណូលក្នុងប្រទេសសរុប....................................២៤ ០៩២ ៦៦៥លានរៀល
  + ចំណូលចរន្ត............................................២៣ ៨៩៩ ៣២៤លានរៀល
  + ចំណូលមូលធនក្នុងប្រទេស................................ ១៩៣ ៣៤១លានរៀល
- ចំណាយថវិកាសរុប.......................................... ២៩ ៩៨៩ ៩៣៣លានរៀល
  + ចំណាយចរន្ត............................................. ១៨ ០៣៦ ៨៨៤លានរៀល
  + ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី).......១១ ៩៥៣ ០៤៩លានរៀល
- អតិរេកនៃថវិកាចរន្ត.......................................(+)៥ ៨៦២ ៤៤០លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ..........................(-)៥ ៨៩៧ ២៦៨លានរៀល
- ហិរញ្ញប្បទាននៃឱនភាព...................................(+)៥ ៨៩៧ ២៦៨លានរៀល
  + ហិរញ្ញប្បទានក្រៅប្រទេស......................... (+)៥ ១៩៧ ២៦៨លានរៀល
  + ហិរញ្ញប្បទានក្នុងប្រទេស..............................(+)៧០០ ០០០លានរៀល
    - បញ្ញើរាជរដ្ឋាភិបាល...........................(+)៧០០ ០០០លានរៀល។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •